**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# ផ្ញើជូន

## លោកជំទាវ ខាំ គៀន ព្រមទាំងក្រុមគ្រួសារ

*លោកជំទាវជាទីរាប់អាន,*

ភរិយាខ្ញុំនិងរូបខ្ញុំបានទទួលដំណឹងដ៏ក្រៀមក្រំ ក្តុកក្តួល និងសោកស្តាយរកអ្វីមកប្រៀបផ្ទឹមពុំបាន ពេលទទួលដំណឹងថា ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ូ ឆន** សមាជិកព្រឹទ្ធសភាបានទទួលមរណភាពក្នុងជន្មាយុ ៨២ ឆ្នាំ ដោយរោគាពាធ ។

មរណភាពរបស់ឯកឧត្តម គឺជាការបាត់បង់ស្វាមី បិតា ជីតាដែលប្រកបដោយព្រហ្មវិហារធម៌ និងជាការបាត់បង់ឥស្សរជនស្នេហាជាតិដ៏ឧត្តុង្គឧត្តមដែលបានបូជាកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញា ស្មារតី និងហ៊ានបូជាជីវិតក្នុងបុព្វហេតុតស៊ូរំដោះប្រទេសជាតិ និងប្រជាជនកម្ពុជាពីរបបប្រល័យពូជសាសន៍ ហើយបានរួមចំណែកយ៉ាងសកម្មក្នុងការស្តារ និងអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យ ។ ទន្ទឹមនេះ ឯកឧត្តមបានខិតខំលើកកម្ពស់សិទ្ធិសេរីភាពគ្រប់បែបយ៉ាងរបស់បងប្អូនជនជាតិភាគតិច ហើយបានចូលរួមប្រែក្លាយតំបន់ភូមិភាគឦសានឱ្យក្លាយជាតំបន់មានការអភិវឌ្ឍដ៏ឆាប់រហ័ស ។ ឯកឧត្តមបានបន្សល់ទុកនូវស្នាដៃជាច្រើនក្នុងការបម្រើស្ថាប័នព្រឹទ្ធសភា ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ភរិយាខ្ញុំ និងរូបខ្ញុំ សូមចូលរួមចែករំលែកនូវមរណទុក្ខដោយក្តីស្រណោះ និងការអាឡោះអាល័យជាមួយលោកជំទាវ និងបុត្រា បុត្រី ព្រមទាំងបងប្អូនកូនក្មួយទាំងអស់នៃសព ដោយសេចក្តីសង្វេគជាទីបំផុត ។

ភរិយាខ្ញុំ និងរូបខ្ញុំ សូមឧទ្ទិសបួងសួងអោយដួងវិញ្ញាណក្ខន្ធឯកឧត្តម **ម៉ូ ឆន** បានឆាប់ចាប់កំណើតក្នុងសុគតិភពគ្រប់ៗជាតិកុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកជំទាវទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីភរិយាខ្ញុំ និងរូបខ្ញុំ ៕

*ថ្ងៃ ព្រហស្បតិ៍ ១៤ កើត ខែ ភទ្របទ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៩*

**ហ៊ុន សែន**